**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខ : ០១៥/២០ ប.ស.ស

# សេចក្តីជូនដំណឹង

## ស្តីពី

## កែសម្រួលនីតិវិធីនៃការជូនដំណឹងជាមុនសម្រាប់ទទួលប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលជូនកម្មករនិយោជិតជាស្ត្រីក្នុង និងក្រៅប្រព័ន្ធពេលសម្រាលកូន

បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) មានកិត្តិយស សូមជម្រាបជូន កម្មករ និយោជិតជាស្ត្រីក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ បានជ្រាបថា ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលជូនកម្មករ និយោជិតជាស្ត្រីក្នុង និងក្រៅប្រព័ន្ធ កាន់តែលឿនទាន់ពេលវេលា ងាយស្រួល និងមានប្រសិទ្ធភាពដល់សាមីខ្លួន **ប.ស.ស.** សូមធ្វើការណែនាំអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ទី១.កម្មករ និយោជិតជាស្ត្រី ឬសាច់ញាតិរបស់ខ្លួន ក្នុងអំឡុងពេលយ៉ាងយូរ៣(បី)ខែមុនសម្រាល ត្រូវអញ្ជើញមកយក **ពាក្យស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលពេលសម្រាលកូន** នៅទីស្នាក់ការ**ប.ស.ស.**ក្នុងរាជធានី ខេត្ត ខណ្ឌ

ទី២.ក្រោយពេលសម្រាលកូនរួច សាមីខ្លួន ឬសាច់ញាតិរបស់ខ្លួន ត្រូវយក **ពាក្យស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលពេលសម្រាលកូន** ដែលមានហត្ថលេខានិងឈ្មោះរបស់គ្រូពេទ្យបញ្ជាក់ថា **សាមីខ្លួនពិតជាបានសម្រាលកូនពិតប្រាកដ** យកមកដាក់នៅទីស្នាក់ការ **ប.ស.ស.** ក្នុងរាជធានី ខេត្ត ខណ្ឌ

ទី៣.សុពលភាពទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលនេះ មានរយៈពេល ១(មួយ)ខែ បន្ទាប់ពីថ្ងៃសម្រាលកូនរួច

ទី៤.**ប.ស.ស.**ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមនេះធ្វើឡើងតាមរយៈធនាគារអេស៊ីលីដា ភីអិលស៊ី តាមគណនីរៀល និងគណនីលីហ្សរេលុយ ដែលភ្ជាប់ជាមួយលេខទូរស័ព្ទរបស់សាមីខ្លួនឲ្យបានច្បាស់លាស់

ទី៥.សេចក្តីជូនដំណឹងនេះ អនុវត្តចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០តទៅ។

បេឡាជាតិសន្តិសុខសង្គមសង្ឃឹមថា កម្មករនិយោជិតជាស្ត្រីក្នុង និងក្រៅប្រព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹង នេះប្រកបដោយស្មារតីខ្ពស់ ។

ថ្ងៃសុក្រ ៧ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ , ០២៣ ៩៩ ៥២ ១៩ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh